ក្នុងចំការមានសុទ្ធតែផ្លែវែងទាំងអស់។ ក្នុងមួយគុម្ព យើងទុកតែមួយ ដើមទេ។







- នៅពេលចេញក្តិប តែងតែមានត្រួយល្ហុងដុះចេញតាមធាងនៃដើមល្ហុង។ យើងត្រូវបេះវាចេញដើម្បីអោយផ្លែល្ហុងរីកធំល្អ និងផ្លែច្រើន។




## ៤~ ការប្រមូលផល :

- រយះពេលពី ៥-៦ ខែយើងអាចប្រមូលផលបានចំពោះតែល្ហុងពូជផ្លែខ្ចី។ បើចង់បេះទុំ គឺយើងទុករយះពេល ៧ខែទើបអាចបេះទុំបាន។
- ពេលបេះផ្លែអស់ហើយយើងត្រូវបាញ់ជីវ៉ែគម្តងទៀតក្នុងកំរិតប្រើ ១00cc លាយជាមួយទឹក



២0L បាញ់តែគល់ល្ហុងទេ ហាមបាញ់លើផ្កា និងក្តិបដែលអាចបណ្តាលអោយរុះផ្កា និងផ្លែក្តិប។ មុនពេលបាញ់ជីយើងត្រូវស្រោចទឹក អោយជោគគល់សិនទើបយើងបាញ់ជីនេះតាមក្រោយ។ ការបាញ់ជី ក្រោយពេលប្រមូលផល សំរាប់ជំនួយដល់ការចេញផ្កា ក្តិប និងអោយផ្លែធំម្តងទៀត។

## អាចរកទិញកូនល្ហុងបានតាមរយះ

១- អ្នកស្រី **ជា ធារិទ្ធ**, អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, ក្បែរស្ពានទឹកវិល, ខ័ណ្ឌ-ក្រុងសៀមរាប, ទូរស័ព្ទលេខ: ០១២ ៣៥ ១០ ៣០ ឬ ០១៧ ៦៨ ៨៤ ៤៩

២- លោក គឹម **សុធា**, អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, សួនបុប្ផាអង្គរ, ក្រុងសៀមរាប, ទូរស័ព្ទលេខ: ០១២ ៩៨ ០៦ ២៣

៣- លោក គឹម ឈុំ, អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, សួនច្បារអេដែន, ក្រុងសៀមរាប, ទូរស័ព្ទលេខ: ០១២ ៣១ ២០ ៥៥

**សំរបសំរួលដោយ**

**កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ខេត្តសៀមរាប**



# ភាពជោគជ័យនៃការដាំល្ហុង



## ការណែនាំអនុវត្តន៍ជាក់ស្តែងជាជំហ៊ានៗដោយះ

លោក ជួប វិចិត្រ, កសិករដាំល្ហុងនៅឃុំតាគ្រែ, ស្រុក កំរៀង, ខេត្តបាត់ដំបង
ទូរស័ព្ទ: ០១១ ៤៤ ៩៤ ៥៤

# ដំណាំល្ហុង

## ១. ការរៀបចំដីដាំល្ហុង:

- យើងត្រូវភ្ជួរហាលដីទុកចោលចំនួន ១ ខែ ទៅ ១ ខែ កន្លះសិន ដើម្បីអោយងាប់សត្វល្អិត និង ស្មៅ រលួយបានល្អ។ យើងត្រូវ ភ្ជួរដីមួយលើកទៀត នៅពេលដែលជិតដាំកូនល្ហុង។
- យើងត្រូវទាញខ្សែអោយត្រង់ ដើម្បីងាយស្រួល ក្នុងការដាំដំណាំផ្សេងទៀត ក្រោមដើមល្ហុង។
- ចន្លោះពីដើមមួយទៅដើមមួយទៀត ប្រវែង ៣ ម៉ែត្រ។
- យើងត្រូវដោតបង្គោលចំណាំរណ្ដៅដែលយើង វាស់រួចហើយ យកជីវ៉ែត ចំនួន ៥00cc លាយ ទឹក ២0L មកបាញ់អោយជោគ ចំបង្គោលរណ្ដៅ ទំហំ២តឹក ៤ជ្រុង រួចទុករយះពេល ៧ថ្ងៃ ទើប យើងកាប់រណ្ដៅ។ មុនបាញ់ជី ត្រូវស្រោចទឹកចំ កន្លែងរណ្ដៅអោយជោគសិន ទើបបាញ់ជីវ៉ែត ដើម្បីអោយ ជីជ្រាបចូលទៅក្នុងដីបានល្អ វាធ្វើ អោយ ដីផុសល្អសំបូរជីជាតិ និងសត្វជន្លេន។






## ២. ការដាំកូនល្ហុង:

- កាប់រណ្ដៅដែលយើងស្រោចជីហើយ ទំហំ ២តឹក ជំរៅ ២តឹក កាប់បំផុសដីអោយម៉ត់ ដោយលាយ ជាមួយជីអាចម៍គោពុកល្អ។
- កូនល្ហុងអាយុពី ១ខែកន្លះ ទៅ២ ខែមាន ប្រវែង មួយចង្អាមដៃ។ យើងត្រូវស្រោចទឹកអោយជោគ មុនយកទៅដាំ។
- យកថង់ចេញ ដោយកុំអោយបែកអាចម៍ដី និង ដាច់ឫសល្ហុងបណ្ដាលអោយកូនល្ហុងងាប់បាន។
- កប់កូនល្ហុងអោយលិចជីកន្ដោង រួចយកអាចម៍ ដីមកពូនសង្កត់អោយណែន បន្ទាប់មកស្រោចទឹក អោយជោគ។
- ត្រូវស្រោចទឹកជារៀងថ្ងៃ នៅពេលល្ងាចអោយ ជោគល្មម។

## ៣. ការថែទាំដើមល្ហុង:

- ក្រោយដាំរួច យើងត្រូវបាញ់ថ្នាំការពារសត្វ ល្អិត "ណាតូ" ក្នុងកំរិតប្រើ ៣0cc លាយជាមួយទឹក ១៦L បាញ់ទៅលើកូនល្ហុង ដើម្បីការពារកុំអោយ សត្វល្អិតស៊ី ឫកាត់ដើមល្ហុងចោល រៀងរាល់៥ ទៅ៧ថ្ងៃម្ដងរហូតដល់កូនល្ហុងមានដើមប៉ុនចង្កើះ។
- ដាំបានរយះពេល ១ខែ បើមានស្មៅដុះជុំវិញគល់ ល្ហុង យើងត្រូវដកវាចេញអោយអស់ ពីព្រោះបើ ទុកវាធ្វើអោយដើមល្ហុងមានការលូតលាស់យឺត។
- ក្រោយពេលសំអាតស្មៅរួចហើយយើងត្រូវជ្រុំ ពូន គល់ល្ហុងម្ដង។ រយះពេល ២ខែបន្ទាប់ពីដាំ ដើម



ល្ហុងមានកំពស់ត្រឹមជង្គង់ យើងត្រូវធ្វើស្មៅ តាម គល់ល្ហុង និងជ្រុំពូនគល់ ម្ដងទៀតជាការស្រេច ព្រោះល្ហុងជិតចេញផ្កាហើយ។

- បន្ទាប់ពីជ្រុំពូនគល់លើកទី២រួចហើយ យើងត្រូវ ស្រោចទឹកតាមគល់ល្ហុងអោយជោគសិន ទើប យើងយកជីវ៉ែត មកបាញ់ម្ដងទៀត។ បាញ់ម្ដង នេះគឺធ្វើអោយដើមល្ហុងធំរឹងមាំ ហើយជំនួយ ដល់ការចេញផ្កា ធ្វើអោយផ្កាច្រើន មិនរុះ ហើយ កាន់ផ្លែល្អ និង អោយល្ហុងមាន រសជាតិផ្អែម មួយ កំរិតទៀត។ ត្រូវលាយជី វ៉ែត ១00cc ជាមួយ ទឹក ២0L ដូចមុន បាញ់អោយសព្វត្រួយ ដើម និង គល់ល្ហុងអោយ សើមជោគ។




- រយះពេល ២ខែកន្លះទៅ ៣ខែល្ហុងចាប់ផ្ដើម ចេញផ្កាហើយ នៅពេលចេញផ្កា យើងអាច កំណត់ថាដើមមួយណាមានផ្លែវែង ហើយដើម មួយណាមានផ្លែខ្លី។ បើដើមណាមានផ្កាល្ហុង រាង ទ្រវែងដូចកដបយើងទុកវា បើផ្កាល្ហុងមានរាង មូលខ្លីធំ យើងកាប់ដើមនោះចេញ នោះទើបល្ហុង